ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣✵៤

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ២៥៧ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការបង្កើតការិយាល័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារ ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានសុខុមាលភាពកុមារ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកម /០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ១០៥ សកបយ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការប្រឹក្សាការ ថែទាំជំនួសចំពោះកុមារ
- បានឃើញប្រកាសលេខ ២១៧ សអយ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ
- បានឃើញប្រកាសលេខ ៦១៦ សអយ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ស្តីពីបទដ្ឋានអប្បបរមាសំរាប់ការថែទាំជំនួសចំពោះកុមារក្នុងមណ្ឌល
- បានឃើញប្រកាសលេខ ១៩៨ សអយ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ២០០៨ ស្តីពីបទដ្ឋានអប្បបរមាសំរាប់ការថែទាំជំនួស ចំពោះកុមារក្នុងសហគមន៍
- បានពិនិត្យការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១ :** បង្កើតការិយាល័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារ ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានសុខុមាលភាពកុមារ នៃអគ្គនាយកដ្ឋានបច្ចេកទេស ។

**ប្រការ ២ :** ការិយាល័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារ មានភារកិច្ច

- ត្រួតពិនិត្យ និង វាយតំលៃការអនុវត្តន៍គោលនយោបាយ និង បទដ្ឋានអប្បបរមា នៃការថែទាំជំនួសចំពោះកុមារ



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

- រៀបចំចាត់ចែងផ្សព្វផ្សាយគោលនយោបាយ បទដ្ឋានអប្បបរមា នៃការថែទាំជំនួសចំពោះកុមារ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធទៅនឹងការងារថែទាំជំនួសចំពោះកុមារ
- រៀបចំតាក់តែងសេចក្តីណែនាំ និងទម្រង់ផ្សេងៗ សំរាប់ក្រុមអធិការកិច្ចចុះអនុវត្តតាម ខេត្ត ក្រុង
- រៀបចំកម្មវិធី និងចុះធ្វើអធិការកិច្ចតាមកាលកំណត់
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង អំពីលទ្ធផលនៃការចុះធ្វើអធិការកិច្ច
- វិភាគស្ថានភាពកុមារដែលស្ថិតក្នុងការថែទាំជំនួសព្រមទាំងការលំបាក ចំណុចខ្លាំង ចំណុចខ្សោយ ក្នុងការផ្តល់ការថែទាំជំនួស និងផ្តល់អនុសាសន៍ឱ្យកែលំអ
- លើកសំណើជូនថ្នាក់ដឹកនាំ ក្រសួង ដើម្បីសុំគតិណែនាំ និងមានវិធានការអនុវត្តបន្តចំពោះស្ថាប័ន អនុវត្តដែលមិនមានការកែប្រែការខុះខាត
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពព័ត៌មានទិន្នន័យពាក់ព័ន្ធនឹងការថែទាំជំនួសចំពោះកុមារ
- រៀបចំ និងធ្វើកំណត់ហេតុប្រជុំរបស់គណៈកម្មាធិការប្រឹក្សាការថែទាំជំនួសចំពោះកុមារ
- សម្របសម្រួលការងារក្រុមការងារជំនាញរបស់គណៈកម្មាធិការប្រឹក្សាការថែទាំជំនួសចំពោះកុមារ
- ធ្វើរបាយការណ៍អំពី លទ្ធផលការងាររបស់គណៈកម្មាធិការប្រឹក្សាការថែទាំជំនួសចំពោះកុមារ ដាក់ជូនថ្នាក់ ដឹកនាំក្រសួង ។

**ប្រការ ៣ :** ការិយាល័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ៤ :** ការិយាល័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារមានមន្ត្រីបំរើការងារផ្ទាល់របស់ខ្លួន ។ ក្នុងករណីចាំបាច់ និងដើម្បីប្រសិទ្ធិភាពការងារ ការិយាល័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារអាចស្នើសុំកិច្ច សហការពីមន្ត្រីការិយាល័យផ្សេងៗទៀតនៃនាយកដ្ឋានសុខុមាលភាពកុមារក្នុងពេលចុះអធិការកិច្ច ។

**ប្រការ ៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦ :** នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃ អគ្គនាយកដ្ឋានបច្ចេកទេស ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសុខុមាលភាពកុមារមានភារកិច្ចអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ខុទ្ទកាល័យ ឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- អាជ្ញាធរសវនកម្មជាតិ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលា ខេត្ត-ក្រុង
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**